# មេរៀនទី៥៤៖ ព្រះគង់នៅជាមួយយើង

## យ៉ូហាន ១៖១-១៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/kIX4PnWSeBQ

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/BVPTVa6V8WM

**គោលបំណង៖** ព្រះយេស៊ូវជាព្រះរបស់យើងរាល់គ្នា

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៖១** *"កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះ ឯងជាព្រះទ្រង់គង់នៅជាមួយនឹងព្រះ"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវគឺជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

២. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0

៣. ខ្ញុំរត់ពីព្រះជាម្ចាស់មិនបាន https://youtu.be/e3O9GqwVGCk

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត

**«នរណាខ្លាំងជាងគេ ?»**



១. ឲ្យកុមារទាំងអស់ឈរនៅចំកណ្តាលថ្នាក់រៀន។

២. គ្រូនឹងលើកយកសត្វពីរផ្សេងគ្នាមកនិយាយ។ កុមារនឹងជ្រើសរើសយកសត្វមួយដែលពួកគេគិតថាខ្លាំងជាងគេដោយដើរទៅទៅខាងស្តាំឬខាងឆ្វេង (តាមរយៈការបង្ហាញផ្លូវរបស់គ្រូ)។

ក. ស្រម៉ោច និង ឆ្កែ

ខ. ឆ្កែ និង ឆ្កែចចក

គ. ទន្សាយ និង ខ្លាឃ្មុំ

ឃ. ក្តាន់ និង មនុស្ស

ង. កញ្ជ្រោង និង គោ។

### ៤. ការណែនាំមេរៀន

តើប្អូនៗប៉ុន្មាននាក់ដែលអាចរាប់ឈ្មោះសត្វបាន២០ក្នុងរយៈពេល១នាទី ? *( គ្រូអាចរើសកុមារមួយចំនួន )* តើប្អូនៗប៉ុន្មាននាក់ ដែលអាចរាប់ឈ្មោះដើមឈើបាន២០ក្នុងរយៈពេល១នាទី ? *( គ្រូអាចរើសកុមារមួយចំនួន )* តើប្អូនដឹងទេ ថាសត្វនិងដើមឈើកើតមកពីណា ?ហើយអ្នកបង្កើតវាមុនដំបូងជានរណា ? នៅក្នុងថ្ងៃនេះអ្នកគ្រូចង់នាំប្អូនៗទៅស្តាប់រឿងជាមួយគ្នា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះគម្ពីរ **យ៉ូហាន ១៖១** ចាប់ផ្តើមដូចគ្នានឹងព្រះគម្ពីរលោកុប្បត្តិ( ជាកណ្ឌគម្ពីរដំបូងក្នុងព្រះគម្ពីរ) "កាលដើមដំបូង" ។ ព្រះគម្ពីរយ៉ូហានពន្យល់ថា កាលដើមដំបូងមានព្រះបន្ទូល។ ព្រះបន្ទូលគឺនៅទីនោះតាំងពី ដើមដំបូងមុនការបង្កើតផែនដី។ ដូច្នេះ តើព្រះបន្ទូលជានរណា? សូមអានព្រះគម្ពីរ **យ៉ូហាន ១៖១-២** ជា មួយគ្នា *"កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូល នោះឯងជា ព្រះ ទ្រង់គង់នៅជាមួយនឹងព្រះតាំងអំពីដើមមក"*។

ខគម្ពីរនេះកំពុងប្រាប់យើងថា នៅដើមដំបូង មុនពេលមានអ្វីៗផ្សេងទៀត នៅពេលនោះគឺមានព្រះ គឺមាននរណាម្នាក់នៅជាមួយព្រះ ហើយម្នាក់នោះគឺជាព្រះអង្គផ្ទាល់។ យើងដឹងថា ខគម្ពីរនេះនិយាយអំពីព្រះយេស៊ូវ ហើយខគម្ពីរជួយយើងឲ្យរៀនអំពីសេចក្តីពិតដ៏សំខាន់មួយអំពីព្រះយេស៊ូវ។ ព្រះយេស៊ូវគឺជាព្រះទ្រង់ផ្ទាល់ ហើយទ្រង់ជាព្រះជានិច្ច។ ទ្រង់គឺជាព្រះពេញលក្ខណៈ។ តើអ្នកអាចនិយាយការពិតនេះជាមួយខ្ញុំបានទេ? **ព្រះយេស៊ូវគឺជាព្រះ។**

ព្រះគម្ពីរ **យ៉ូហាន ១៖១៤** ចែងថា "ព្រះបន្ទូលបានត្រលប់ជាសាច់ឈាម" ។ ព្រះយេស៊ូវដែលយើងទើបតែ និយាយថា ជាព្រះបានក្លាយទៅជាមនុស្ស។ នេះគឺជាពាក្យដ៏ធំមួយសម្រាប់អ្នក - **ការចាប់កំណើត**។ ពាក្យនេះមានន័យថាការកើតជារូបរាង។ ដូច្នេះ យើងអាចនិយាយបានថា ព្រះយេស៊ូជាព្រះដែលចាប់ កំណើត ឬជាព្រះក្នុងរូបកាយជាមនុស្ស។ ព្រះយេស៊ូបានក្លាយជាមនុស្ស ហើយបានត្រលប់ជាសាច់ ឈាម ដោយចាប់កំណើតជាទារកតូចមួយ។ ព្រះអង្គបានកើតជាទារកដែលនឹងធំឡើង ដើម្បីជាព្រះអង្គសង្គ្រោះ—ជាអ្នកដែលព្រះវរបិតាបានចាត់ឲ្យមកសង្គ្រោះរាស្ត្ររបស់ទ្រង់។

ព្រះគម្ពីរ **យ៉ូហាន ១៖១៤** ចែងថាព្រះយេស៊ូវ "គង់នៅក្នុងជាមួយយើងគ្រប់គ្នា" ។ នេះមានន័យថាព្រះយេស៊ូវបានយាងមកគង់នៅជាមួយនឹងយើងរាល់គ្នា ហេតុអ្វីបានជារឿងនេះអស្ចារ្យ? វាជារឿងដ៏អស្ចារ្យព្រោះព្រះគឺ បរិសុទ្ធ។ ព្រះយេស៊ូវគឺបរិសុទ្ធ។ ហើយដោយសារអំពើបាបយើងមិនបរិសុទ្ធទេ។ ព្រះបរិសុទ្ធ បានយករូបកាយមិនបរិសុទ្ធ ហើយមករស់នៅជាមួយនឹងមនុស្សមិនបរិសុទ្ធ។ ព្រះអង្គបានមករស់នៅជាមួយ មនុស្សមានបាប។ ព្រះយេស៊ូវបានយាងមក ដើម្បីបង្ហាញផ្លូវយើងទៅឯព្រះវរបិតា។ ព្រះយេស៊ូវបានយាង មកផែនដីដើម្បីរស់នៅជាមួយរាស្ត្ររបស់ទ្រង់ ហើយបានសង្គ្រោះពួកគេពីអំពើបាប និងសេចក្តីស្លាប់ ។ ហើយព្រះអង្គអាចសង្គ្រោះយើងបាន ដោយសារព្រះយេស៊ូវគឺជាព្រះ!

## ៦. សំនួរពិភាក្សា

១. តើព្រះគម្ពីរ យ៉ូហាន ១៖១ និយាយថាមានអ្វីកាលពីដើមដំបូងឡើយ? *(ព្រះបន្ទូល)*

២. តើព្រះបន្ទូលត្រឡប់ទៅជាអ្នកណា? *(ព្រះយេស៊ូវ)*

៣. តើអ្វីទៅជាការអស្ចារ្យពី "ការចាប់កំណើត" របស់ព្រះយេស៊ូវ? *(ព្រះបរិសុទ្ធបានយករូបកាយមិនបរិសុទ្ធហើយមករស់នៅជាមួយនឹងមនុស្សមានបាប)*

៤. ហេតុអ្វីបានជាព្រះយេស៊ូវយាងមករស់នៅជាមួយមនុស្ស? *(ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីអំពើបាប និងសេចក្តីស្លាប់)*

## ៧. ល្បែងកំសាន្ត «តើអ្នកអាចផ្លាស់ប្តូរបានលឿនប៉ុណ្ណា?»

១. បែងចែកកុមារជាពីក្រុម

២. ក្រុមនីមួយៗត្រូវឲ្យកុមារ៣នាក់ចេញមកឈរនៅខាងមុខ

៣.ពេលដែលគ្រូនិយាយ ប្អូនៗត្រូវផ្លាស់ប្ដូរតាមពាក្យគ្រូឲ្យលឿន។ ឧទាហរណ៍៖ បើសិនជាគ្រូនិយាយ ថា "ទន្សាយ" ប្អូនៗត្រូវប្ដូរកាយវិការទៅជាសត្វទន្សាយ។ បើកុមារទាំង៣នាក់ នៅក្នុងក្រុមតែមួយអាចប្ដូរកាយវិការបាននោះក្រុមពួកគេនឹងបានពិន្ទុ។(កុមារអាចធ្វើការរួមគ្នាដើម្បី ជ្រើសរើសអ្វីដែលពួកគេចង់ ធ្វើ)



ក. ជារង្វង់

ខ. ខ្លា

គ. ពស់

ឃ. ការ៉េ

ង. ស្រមោច

ច. ឥន្ទ្រី

ឆ. ក្រពើ

៤. ក្រោយពីលេងល្បែងចប់ សូមពន្យល់កុមារថា វាមិនងាយស្រួលក្នុងការផ្លាស់ប្ដូរទៅជាអ្វី ដែលមិនមែនជាយើងនោះ។ យើងត្រូវតែដឹងគុណដល់ព្រះដែលមានអំណាចបំផុតបានមកយកកំណើតជាមនុស្ស ដើម្បីសង្គ្រោះយើងរាល់គ្នាពីអំពើបាប និងសេចក្ដីស្លាប់។

### ៨. ខគម្ពីរចងចាំ

**យ៉ូហាន ១៖១** *"កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះទ្រង់គង់នៅជាមួយនឹងព្រះ"*។

### ៩. ហាត្ថកម្ម

(សូមផាត់ពណ៌រូបភាព)ព្រះយេស៊ូវជាព្រះរបស់យើងរាល់គ្នានៅទំព័រខាងក្រោម។

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ព្រះដែលគ្រប់បរិសុទ្ធបានក្លាយជាមនុស្សដែលមិនបរិសុទ្ធ ហើយយាងមកផែនដីរស់នៅជាមួយមនុស្សមិនបរិសុទ្ធដូចអ្នក និងខ្ញុំ។ នេះជាការពិតដ៏អស្ចារ្យមួយដែលយើងតែងភ្លេចញឹកញាប់។ ព្រះយេស៊ូវជាព្រះហើយជាស្ដេចលើអស់ទាំងស្ដេច។ ព្រះអង្គមិនចាំបាច់ត្រូវយាងមករកយើងដូចជា ទារកដែលមិនអាចជួយអីបាននោះទេ ប៉ុន្តែព្រះអង្គបានមករកយើងដោយទ្រង់ស្រឡាញ់យើង។ សូមអធិស្ឋានអរព្រះគុណ ព្រះយេស៊ូវនៅថ្ងៃនេះដែលទ្រង់ស្រឡាញ់យើង ហើយទ្រង់យាងមករកយើងនៅថ្ងៃបុណ្យណូអែល។

# ព្រះយេស៊ូវជាព្រះរបស់យើងរាល់គ្នា



សូមសរសេរខគម្ពីរចងចាំៈ______________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________